# កិច្ចប្រជុំរួមគ្នារវាង
# រចនាសម្ព័ន្ធ ជាតិ និង អន្តរជាតិ ដែលទាក់ទងនឹងក្រមសីលធម៌
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## របាយការណ៍
## ជូន
## ក្រុមការងាររាជរដ្ឋាភិបាលកម្ពុជា និង គណៈកម្មាធិការអចិន្ត្រៃយ៍
## រៀបចំដោយក្រុមការងារជាតិ

នៅក្នុងកិច្ចប្រជុំថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០០៨ **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី និង ជាប្រធានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាសំរាប់សាលាក្តីខ្មែរក្រហម និង លោក Peter Taksoe-Jensen ឧបការីលោកអគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកការងារច្បាប់ បានយល់ព្រមបង្កើតកិច្ចប្រជុំរួមគ្នារវាងរចនាសម្ព័ន្ធជាតិ និងអន្តរជាតិដែលទាក់ទងនឹងក្រមសីលធម៌នៃ អ.វ.ត.ក ដើម្បីធានាថារដ្ឋបាលទាំងមូលដំណើរការកាន់តែមានតម្លាភាព និងប្រសិទ្ធិភាព។ ភាគីទាំងពីរព្រមព្រៀងគ្នាថាវិធានការទាំងនេះនឹងអនុលោមតាមនីតិវិធីនៃច្បាប់ និង ធានាបាននូវការការពារចាំបាច់ ។ ភាគីទាំងពីរបានព្រមព្រៀងលើភាពចាំបាច់ក្នុងការដោះស្រាយបញ្ហាទាំងនេះជាបន្ទាន់ និង រំពឹងថាលទ្ធផលនៃកិច្ចប្រជុំរួមគ្នានឹងត្រូវរាយការណ៍ទៅអោយក្រុមការងាររាជរដ្ឋាភិបាល និងគណៈកម្មាធិការអចិន្ត្រៃយ៍នៅដំណាច់ខែមករា ឆ្នាំ២០០៩ ។

នៅដើមខែមករា លោក Peter Taksoe-Jensen បានតែងតាំងលោក Rajeev Kumra និងលោកស្រីWendy Lobwein (អ្នកទាំងពីរជាមន្ត្រី UNAKRT) និង លោកស្រី Patricia Georget (មន្ត្រីនៃការិយាល័យកិច្ចការច្បាប់ (OLA) និង បច្ចុប្បន្ននេះធ្វើការជាមួយ UNAKRT) ជាក្រុមការងារអ.ស.ប ចំណែក**ឯកឧត្តម សុខ អាន** បានតែងតាំងមន្ត្រីត្រួតពិនិត្យក្រមសីលធម៌ទាំងពីរ (ឯកឧត្តមគង់ ស្រ៊ុម និង លោកជំទាវ ហៃឡែន ចាវីស) និង មន្ត្រីច្បាប់ជាតិ ជាសមាជិកនៃក្រុមការងារជាតិ ។

កិច្ចប្រជុំរួមគ្នាលើកទី១ ត្រូវបានធ្វើឡើងនៅថ្ងៃទី១៤ ខែមករា ឆ្នាំ ២០០៩ និងជួបជាបន្តបន្ទាប់ចំនួន ៥លើក ហើយកិច្ចប្រជុំចុងក្រោយគឺធ្វើឡើងនៅថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០០៩កន្លងទៅនេះ ។

នៅក្នុងកិច្ចប្រជុំលើកទី១ ក្រុមការងារ អ.ស.ប បានស្នើអោយមានការបង្កើត *"វេទិកាគ្រប់គ្រងដោយតម្លាភាពថ្មីមួយ សម្រាប់ អ.វ.ត.ក ដែលត្រូវមានធាតុផ្សំចំនួនបីៈ មន្ត្រីក្រមសីលធម៌អន្តរជាតិឯករាជមួយរូប គណៈកម្មាធិការក្រមសីលធម៌មួយ និងអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក"*

នៅថ្ងៃទី ២០ ខែមករា ក្រុមការងារជាតិបានធ្វើជូននូវការឆ្លើយតបរបស់ខ្លួន ដែលបានបញ្ជាក់នូវការយល់ឃើញថា *"ការយល់ឃើញរបស់យើងពីសេចក្តីប្រកាសរួមគ្នាគឺ អ.ស.ប នឹងបង្កើតនូវយន្តការមួយស្របគ្នានឹង [មន្ត្រីត្រួតពិនិត្យក្រមសីលធម៌ជាតិ] នៅក្នុង អ.វ.ត.ក និងយោងទៅនឹងវចនាសម្ព័ន្ធនៅពីរដំណាក់កាលផ្សេងទៀត. .. ..ដោយអនុលោមតាមទស្សនៈខាងលើនេះ យើងបានអញ្ជើញមន្ត្រី អ.ស.ប ដែលបានតែងតាំង បន្តធ្វើការក្នុងកិច្ចប្រជុំរួមគ្នានេះជាមួយមន្ត្រីជាតិដែលបានតែងតាំង លើរបៀបវារៈដូចខាងក្រោមៈ*

*ពិនិត្យ និងពិចារណាលើមតិយោបល់ និង ការណែនាំ លើវចនាសម្ព័ន្ធជាតិ និង អន្តរជាតិដែលពាក់ព័ន្ធ តាមករណីសមស្រប ។*

*ពិភាក្សាបញ្ហាផ្សេងទៀត ឧទាហរណ៍ ការបង្កើតយុទ្ធសាស្ត្ររួមគ្នា ផែនការសកម្មភាព និងនីតិវិធីរាយការណ៍ ។ល។*

នៅថ្ងៃទី២៦ ខែមករា ក្រុមការងារ អ.ស.ប បានធ្វើការបង្ហាញសំណើដែលបានកែប្រែជាថ្មីរបស់ខ្លួននិង បានស្នើអោយក្រុមការងារជាតិផ្តល់នូវសំណើតប ដែលយើងក៏បានផ្តល់ជូនកាលពីថ្ងៃទី២៨ ខែមករា ហើយយើងខ្ញុំកំពុងរងចាំការឆ្លើយតបពីក្រុមការងារ អ.ស.ប ។

កិច្ចប្រជុំរួមគ្នាត្រូវបានធ្វើឡើងដោយលក្ខណៈវិជ្ជមាន ក្រុមការងារទាំងពីរបានធ្វើការរួមគ្នាក្នុងលក្ខណៈស្ថាបនា ដើម្បីបង្កើតសំរេចអោយបានដោយប្រសិទ្ធិភាព និងអាចទទួលយកបានទាំងសងខាងនូវការអនុវត្តលើចំណុចដែលបានឯកភាពគ្នារវាងភាគីទាំងពីរ ដូចមានចែងនៅក្នុងសេចក្តីប្រកាសរួមកាលពីថ្ងៃទី១០ខែធ្នូ ឆ្នាំ ២០០៩ តាមរយៈការពង្រឹងបន្ថែមទៀតលើយន្តការពាក្យបណ្តឹង និងការខិតខំដើម្បីទទួលបាននូវបទដ្ឋានខ្ពស់បំផុតនៃការគោរពក្រមសីលធម៌ទូទាំង អ.វ.ត.ក។

រាជធានីភ្នំពេញ
ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៩